# ប្រកាសលេខ ០៨៦

# ស្តីពីការបង្កើតគណៈកម្ម

# ការអេដស៍នៅតាមសហ

# គ្រាស គ្រឹះស្ថាននិងការ

# បង្ការទប់ស្កាត់ មេរោគ

# អេដស៍ នៅកន្លែងធ្វើការ

# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ ០៨៦ ក.ក.ប.វ/ប្រ.ក

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០៦

## ប្រកាស
## ស្តីពី
## ការបង្កើតគណៈកម្មការអេដស៍នៅតាមសហគ្រាស គ្រឹះស្ថាន និងការបង្ការទប់ស្កាត់ មេរោគអេដស៍/ជំងឺអេដស៍ នៅកន្លែងធ្វើការ

## រដ្ឋមន្ត្រីក្រសួង ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧០៤/០០១ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧០២/០១៥ ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍
- បានឃើញអនុក្រឹត្យលេខ៥២អនក្រ/បក/ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

### ប្រការ ១.-

ប្រកាសនេះមានគោលបំណង បំផុស លើកកំពស់ស្មារតី និងជម្រុញដល់ការអប់រំ និងជួយកម្មករនិយោជិតអំពីការបង្ការ និងការទប់ស្កាត់ ការឆ្លងរីករាលដាល មេរោគអេដស៍/ជំងឺអេដស៍នៅកន្លែងធ្វើការ ។ ៕

**ប្រការ ២.-**

សហគ្រាស គ្រឹះស្ថាន ដូចមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារ ហើយដែលមានប្រើ កម្មករនិយោជិត ចាប់ពី៨នាក់ឡើងទៅ ត្រូវរៀបចំបង្កើតក្រុមការងារអេដស៍ ឬគណៈកម្មការអេដស៍សំរាប់ សហគ្រាស គ្រឹះស្ថាន របស់ខ្លួន ។

**ប្រការ ៣.-**

ចំពោះសហគ្រាស គ្រឹះស្ថាន ដែលមានកម្មករនិយោជិតពី ៨នាក់ដល់៥០នាក់ និយោជក និង សហជីព មូលដ្ឋាន ត្រូវពិគ្រោះគ្នាអំពីការបង្កើតក្រុមការងារអេដស៍សំរាប់សហគ្រាស គ្រឹះស្ថាន របស់ខ្លួនដែលមាន តំណាងនិយោជកចំនួនមួយរូបយ៉ាងតិច និងតំណាងសហជីពមូលដ្ឋានចំនួនមួយរូបយ៉ាងតិច ចូលរួមក្នុងក្រុម ការងារ តំណាងនិយោជកត្រូវទទួលភារកិច្ចជាប្រធានក្រុមការងារ ។

ចំពោះសហគ្រាសគ្រឹះស្ថានដែលមានកម្មករនិយោជិតចាប់ពី ៥១នាក់ឡើងទៅ និយោជក និងសហជីពមូលដ្ឋាន ត្រូវពិគ្រោះគ្នាអំពីការបង្កើតគណៈកម្មការអេដស៍ សំរាប់សហគ្រាស គ្រឹះស្ថាន របស់ខ្លួន ។

គណៈកម្មការនេះ ត្រូវមានតំណាងនិយោជកយ៉ាងតិចចំនួនពីររូប តំណាងសហជីពមូលដ្ឋានចំនួនយ៉ាងតិចពីររូប និងអ្នកទទួលខុសត្រូវគិលានដ្ឋានមួយរូប ចូលរួមជាសមាជិក ។ ចំពោះសហគ្រាស គ្រឹះស្ថាន ដែលមានសហជីព មូលដ្ឋានច្រើន សហជីពនីមួយៗអាចបញ្ជូនតំណាងរបស់ខ្លួនមួយរូប ឱ្យចូលរួមជាសមាជិកគណៈកម្មការ ។

**ប្រការ ៤.-**

គណៈកម្មការអេដស៍ដូចមានចែងក្នុង ប្រការ៣ កថាខ័ណ្ឌទី២ ខាងលើ ត្រូវពិគ្រោះគ្នាអំពីការតែងតាំងប្រធាន ១ រូបរបស់គណៈកម្មការ ។ តំណាងមកពីភាគីនិយោជកគួរតែទទួលបន្ទុកធ្វើជាប្រធានគណៈកម្មការ ។ បើពុំមាន ការឯកភាពគ្នាទេ ការតែងតាំងប្រធានគណៈកម្មការត្រូវប្រព្រឹត្តទៅតាម វិធីចាប់ឆ្នោតដោយសមាជិកទាំង អស់អាចឈរឈ្មោះជាប្រធានគណៈកម្មការតាមការស្ម័គ្រចិត្ត ហើយសរសេរឈ្មោះខ្លួនឯងលើសន្លឹកឆ្នោតម្នាក់ ១សន្លឹករួចយកទៅដាក់ក្នុងហិបឆ្នោតមួយ ។ សមាជិក ដែលមាន អាយុច្រើនជាងគេចាប់យកសន្លឹកឆ្នោត១ សន្លឹកពីក្នុងហិបឆ្នោត រួចប្រកាសឈ្មោះនោះជា ប្រធានគណៈកម្មការ ចាប់ពីពេលនោះតទៅ ។ ករណីមានបេក្ខជនតែមួយរូបឈរឈ្មោះ បេក្ខជននោះត្រូវតែបានទទួលស្គាល់ថាជា ប្រធានគណៈកម្មការដោយស្វ័យប្រវត្តិ ។ ប្រធានគណៈកម្មការមានអាណត្តិ ២ឆ្នាំ ។ ក្នុងអំឡុងពេល ៣០ថ្ងៃមុនចប់អាណត្តិគណៈកម្មការត្រូវប្រជុំពិគ្រោះ គ្នា អំពីការតែងតាំងប្រធានសំរាប់អាណត្តិថ្មី តាមនីតិវិធីដូចមានចែងក្នុងប្រការនេះស្រាប់ ។

ដោយហេតុផលសមស្របណាមួយ ដែលពុំទាន់អាចធ្វើការតែងតាំងប្រធានសំរាប់អាណត្តិថ្មីបាន ប្រធាននៃអាណត្តិចាស់ត្រូវបន្តការងាររបស់ខ្លួនរហូតដល់តែងតាំងបានប្រធានថ្មីមកជំនួស ។ ///

ក្នុងករណីដែលប្រធានគណៈកម្មការអវត្តមាន មិនអាចបំពេញតួនាទីជាប្រធានបាន សមាជិកដែលមានអាយុច្រើនជាងគេត្រូវទទួលភារកិច្ចជាប្រធានស្តីទី ។

ក្នុងករណីមានសមាជិកឈប់ ឬលាលែង ពីតំណែងនៃសមាជិកគណៈកម្មការ ប្រធានត្រូវស្នើសុំទៅ និយោជក ឬសហជីពមូលដ្ឋាន ឱ្យបញ្ជូនឈ្មោះសមាជិកថ្មីមកបំពេញអាសនៈដែលទំនេរ ។

**ប្រការ ៥.-**

ក្រោយពេលបង្កើតក្រុមការងារ ឬគណៈកម្មការអេដស៍ ដូចមានចែងក្នុង ប្រការ៣ និង ប្រការ៤ ខាងលើបានហើយ ប្រធានក្រុមការងារ ឬប្រធានគណៈកម្មការ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងអំឡុងពេល ១៥ថ្ងៃយ៉ាងយូរ ដោយមានភ្ជាប់ទៅជាមួយ នូវបញ្ជីរាយនាមក្រុមការងារ ឬបញ្ជីរាយនាមគណៈកម្មការ តាមតារាងគំរូជាឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ ៦.-**

ចំពោះសហគ្រាស គ្រឹះស្ថាន ដែលពុំទាន់មានសហជីព ពាក្យថា "សហជីពមូលដ្ឋាន" ដូចមានចែងក្នុងប្រការ៣ ខាងលើ ត្រូវជំនួសដោយប្រតិភូបុគ្គលិក ឬតំណាងកម្មករនិយោជិត តាមការស្ម័គ្រចិត្ត ។

**ប្រការ ៧.-**

ក្រុមការងារអេដស៍ និងគណៈកម្មការអេដស៍ ដូចមានចែងក្នុងប្រការ៣ មានតួនាទីភារកិច្ចដូចតទៅ:

**ក.** ផ្សព្វផ្សាយជូនកម្មករនិយោជិតទាំងអស់របស់ខ្លួន ឱ្យបានយល់ជ្រួតជ្រាបអំពីការបង្កើតក្រុមការងារ ឬគណៈកម្មការនេះ និងសមាសភាពរបស់ក្រុមការងារ ឬគណៈកម្មការ ។

**ខ.** ប្រជុំគ្នាតាមពេលវេលាដែលអាចធ្វើបាន ដើម្បីពិគ្រោះពិភាក្សារៀបចំកម្មវិធី សំរាប់អប់រំកម្មករនិយោជិត នៅកន្លែងការងារអំពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការឆ្លងរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ ។

**គ.** លើកសំណើទៅនាយកដ្ឋានពេទ្យការងារ សុំជំនួយបច្ចេកទេស ឯកសារ ឬវិធីសាស្ត្រផ្សេងៗ សំរាប់អប់រំ និងជួយកម្មករនិយោជិតឱ្យយល់ជ្រួតជ្រាបអំពីការបង្ការនិងទប់ស្កាត់ ការឆ្លងរីករាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍ នៅកន្លែងធ្វើការ ។

**ឃ.** យកចិត្តទុកដាក់អប់រំឱ្យបានយល់ជ្រួតជ្រាបមុនគេចំពោះថ្នាក់ដឹកនាំសហជីព ប្រតិភូបុគ្គលិក មេការ ប្រធានផ្នែក ប្រធានក្រុម ប្រធានពួក ហើយបង្កឱកាសដល់អ្នកទាំងនោះធ្វើការអប់រំបន្តដល់កម្មករនិយោជិតជាទូទៅ តាមពេលវេលា និងលទ្ធភាពជាក់ស្តែង ប្រកបដោយភាពយោគយល់គ្នា រវាងនិយោជក និងតំណាងកម្មករនិយោជិត ។ +/S

ង. អប់រំកម្មករនិយោជិតទាំងអស់ អំពីយុទ្ធសាស្ត្រនៃការកាត់បន្ថយគ្រោះថ្នាក់ ដោយផ្តល់នូវពត៌មាន ដែលទាក់ទាញការចាប់អារម្មណ៍ហើយច្បាស់លាស់ និងសមស្របទៅនឹងកាលវេលា ។ ក្នុងករណីចាំបាច់ ត្រូវធ្វើយ៉ាងណាឱ្យបុរសនិងស្ត្រី ងាយរកបាននូវស្រោមអនាម័យនៅពេលត្រូវការប្រើប្រាស់ ។

ច. ជួយដល់កម្មករនិយោជិត ដែលមានផ្ទុកមេរោគអេដស៍ ឬមានកើតជំងឺអេដស៍ ឱ្យទទួលបាននូវសេវាសុខាភិបាលសំរាប់ការព្យាបាល និងការបង្ការការឆ្លងអេដស៍ និងជួយលើកទឹកចិត្តដល់អ្នកទាំងនោះ ឱ្យមានសេចក្តីសង្ឃឹមក្នុងជីវិត បន្តការងារក្នុងស្ថានភាពធម្មតានិងជាប្រក្រតី ។

ឆ. លើកសំណើទៅនិយោជក ទៅក្រសួងស្ថាប័នមានសមត្ថកិច្ច ឬទៅអង្គការនានា ឱ្យជួយដោះស្រាយបញ្ហាដែលគណៈកម្មការមិនអាចដោះស្រាយបាន សំដៅជួយដល់កម្មករនិយោជិតដែលមានផ្ទុកមេរោគអេដស៍ ឬមានជំងឺអេដស៍ តាមការជាក់ស្តែងនៃបញ្ហានីមួយៗ ។

## ប្រការ ៨.-

ប្រធានគណៈកម្មការអេដស៍ដូចមានចែងក្នុង ប្រការ៤ មានតួនាទីភារកិច្ចដូចតទៅ:

ក. ដឹកនាំការប្រជុំលើកដំបូង ដើម្បីរៀបចំកម្មវិធីការងាររបស់គណៈកម្មការ តាមពេលវេលានិងទីកន្លែង ដោយភាពយោគយល់គ្នារវាងនិយោជក និងតំណាងកម្មករនិយោជិត ។

ខ. ចាត់ចែងឱ្យមានសកម្មភាពជាក់ស្តែង ត្រឹមត្រូវតាមកម្មវិធីការងាររបស់ខ្លួន ឬតាមការណែនាំពីនាយកដ្ឋានពេទ្យការងារ ឬពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ។

គ. ទទួលសំណូមពរផ្សេងៗពីសមាជិក ឬពីកម្មករនិយោជិត រួចលៃលកពេលវេលាសមស្របដើម្បីប្រជុំគ្នា ពិគ្រោះដោះស្រាយសំណូមពរទាំងនោះ ។ ក្នុងករណីចាំបាច់ ត្រូវលើកសំណូមពរនោះជូននិយោជក ជូននាយកដ្ឋានពេទ្យការងារ ឬជូនក្រសួង ស្ថាប័នមានសមត្ថកិច្ច ឬអង្គការនានាសុំជួយដោះស្រាយ ។

ឃ. ត្រូវលៃលកពេលវេលាសមស្រប ធ្វើការប្រជុំគណៈកម្មការមួយខែម្តង ឬយ៉ាងយូរមួយត្រីមាសម្តង ដើម្បីត្រួតពិនិត្យការងាររបស់ខ្លួន និងដាក់ចេញនូវវិធានការកែលំអការខ្វះខាតក្នុងករណីចាំបាច់ ដើម្បីជំរុញការងាររបស់គណៈកម្មការមានដំណើរការល្អ ។

## ប្រការ ៩.-

កម្មករនិយោជិត ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមការណែនាំ និងការអប់រំផ្សព្វផ្សាយ របស់ក្រុមការងារអេដស៍ ឬគណៈកម្មការអេដស៍ ឬរបស់នាយកដ្ឋានពេទ្យការងារ ឬរបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ច សំដៅបង្ការ និងទប់ស្កាត់ការឆ្លងរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍នៅកន្លែងធ្វើការ ។

**ប្រការ ១០.-**

កម្មករនិយោជិត អាចលើកសំណើ ឬសំណូមពរផ្សេងៗ តាមការជាក់ស្តែង ដែលពាក់ព័ន្ធនឹងមេរោគអេដស៍ ឬជំងឺអេដស៍នៅកន្លែងធ្វើការ តាមរយៈប្រតិភូបុគ្គលិក ឬសហជីពមូលដ្ឋាននៃសហគ្រាស គ្រឹះស្ថាន របស់ខ្លួន ទៅក្រុមការងារអេដស៍ ឬគណៈកម្មការអេដស៍ ដូចមានចែងក្នុង ប្រការ៣ ឱ្យជួយដោះស្រាយ ។

កម្មករនិយោជិត អាចលើកសំណើ ឬសំណូមពរទាំងនោះ ត្រង់ទៅក្រុមការងារអេដស៍ ឬគណៈកម្មការអេដស៍ នៃសហគ្រាស គ្រឹះស្ថានរបស់ខ្លួនដើម្បីសុំការជួយដោះស្រាយ ។

**ប្រការ ១១.-**

និយោជកនៃសហគ្រាស គ្រឹះស្ថាន ដូចមានចែងក្នុង ប្រការ៣ ខាងលើត្រូវផ្តល់ឱកាសនិងបង្កភាពងាយស្រួល ដល់ក្រុមការងារអេដស៍ ឬគណៈកម្មការអេដស៍ នៃសហគ្រាស គ្រឹះស្ថានរបស់ខ្លួន ឱ្យបំពេញតួនាទីភារកិច្ច ដូចមានចែងក្នុង ប្រការ៧ ឱ្យបានទទួលជោគជ័យ ។

ហាមដាច់ខាត រាល់ការរើសអើងរបស់និយោជក ចំពោះកម្មករនិយោជិត ទាំងបុរស ទាំងស្ត្រី ដែលមានផ្ទុកមេរោគអេដស៍ ឬជំងឺអេដស៍ឡើយ ជាអាទិ៍ ការបញ្ឈប់ពីការងារ ការមិនផ្តល់ការងារឱ្យបានគ្រប់គ្រាន់ ការមិនផ្តល់ប្រាក់ឈ្នួលឱ្យដូចកម្មករនិយោជិតដទៃ ការមិនតម្លើងឋានៈនាទី ការមិនផ្តល់ប្រាក់រង្វាន់ផ្សេងៗ ដោយសារតែសាមីខ្លួនមានផ្ទុកមេរោគអេដស៍ ឬជំងឺអេដស៍ ។

**ប្រការ ១២.-**

គោលការណ៍គន្លឹះសំខាន់ៗ មានដូចតទៅ:

**ក. ការទទួលស្គាល់ថាមេរោគអេដស៍/ជំងឺអេដស៍ជាបញ្ហានៅកន្លែងធ្វើការ**

បញ្ហាមេរោគអេដស៍/ជំងឺអេដស៍នៅកន្លែងធ្វើការ គួរតែទទួលបាននូវការដោះស្រាយដូចជម្ងឺធ្ងន់ធ្ងរ ឬលក្ខខណ្ឌដទៃទៀត នៅកន្លែងធ្វើការ ។ នេះជាការចាំបាច់មួយ ដែលមិនមែនគ្រាន់តែដោយសារការប៉ះពាល់កម្លាំងពលកម្មប៉ុណ្ណោះទេ ប៉ុន្តែកន្លែងធ្វើការជាផ្នែកមួយនៃសហគមន៍មូលដ្ឋាន ដែលត្រូវមានតួនាទីធំធេង ក្នុងការប្រយុទ្ធប្រឆាំង ដើម្បីកាត់បន្ថយការឆ្លងរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ និងដោះស្រាយផលប៉ះពាល់នៃជម្ងឺនេះផងដែរ ។

**ខ. ការមិនរើសអើង**

នៅក្នុងស្មារតីធ្វើឱ្យរាល់ការងារអាចប្រព្រឹត្តទៅក្នុងលក្ខខណ្ឌសមរម្យ ការគោរពសិទ្ធិមនុស្ស និងសេចក្តីថ្លៃថ្នូរបស់បុគ្គលដែលមានមេរោគអេដស៍/ជំងឺអេដស៍ និងអ្នកដែលទទួលរងផលប៉ះពាល់ដោយសារជំងឺនេះ ។ ដូច្នេះ ក្ស

ហើយ បានជាមិនត្រូវមានការរើសអើង ចំពោះកម្មករនិយោជិតដោយផ្អែកលើគតិមាន ថាពួកគេមានមេរោគអេដស៍/ជំងឺអេដស៍ ។ ការរើសអើង និងការប្រមាថមាក់ងាយចំពោះអ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ ជាឧបស័គ្គរាំងដល់ការខិតខំប្រឹងប្រែង ក្នុងការបង្ការ ការឆ្លងរីករាលដាលនៃមេរោគនេះ ។

**គ. សមភាពយេនឌ័រ**

គួរតែបានទទួលស្គាល់មាត្រដ្ឋានយេនឌ័រ ដែលទាក់ទងនឹងមេរោគអេដស៍/ជំងឺអេដស៍ ។ ស្ត្រីងាយទទួលរងគ្រោះជាងបុរសដោយសារលក្ខណៈជីវសាស្ត្រ វប្បធម៌សង្គម និងហេតុផលសេដ្ឋកិច្ច ដែលធ្វើឱ្យស្ត្រីជាអ្នកដែលងាយទទួលរងការឆ្លងមេរោគ និងផលប៉ះពាល់ធ្ងន់ធ្ងរ ដោយការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ ។ ដរាបណាការរើសអើងដល់យេនឌ័រក្នុងសង្គមកាន់តែខ្លាំង និងដរាបណាស្ត្រីមានតួនាទីតូចទាបនៅក្នុងសង្គម ដរាបនោះស្ត្រីកាន់តែងាយរងគ្រោះដោយសារមេរោគអេដស៍/ជំងឺអេដស៍ ។ ដូច្នេះហើយ សមភាពយេនឌ័រ និងការផ្តល់សិទ្ធិជាម្ចាស់ដល់ស្ត្រីជាចំណុចគន្លឹះសំខាន់ក្នុងការធ្វើឱ្យការបង្ការទប់ស្កាត់ ការឆ្លងរីករាលដាលមេរោគអេដស៍ និងជួយឱ្យស្ត្រីអាចដោះស្រាយផលវិបាកនៃជំងឺនេះ ទទួលបានជោគជ័យ ។

**ឃ. បរិយាកាសប្រកបដោយសុខុមាលភាពនៅកន្លែងធ្វើការ**

ដោយអនុលោមតាមអនុសញ្ញាលេខ១៥៥ ស្តីពីសុវត្ថិភាពការងារ និងការបង្ការសុខភាពឆ្នាំ១៩៨១ បរិយាកាសនៅកន្លែងធ្វើការគួរតែប្រកបដោយផាសុខភាពនិងសុវត្ថិភាព ធ្វើយ៉ាងណាឱ្យគ្រប់ផ្នែកទាំងអស់ងាយស្រួលនឹងបង្ការការចម្លងមេរោគអេដស៍ ។

បរិយាកាសប្រកបដោយផាសុខភាពនៅកន្លែងធ្វើការ សម្រួលយ៉ាងប្រសើរដល់ការប្រើប្រាស់កម្លាំងកាយ និងកម្លាំងចិត្តរបស់កម្មករនិយោជិត ក្នុងការបំពេញការងារដោយយោលទៅតាមសមត្ថភាពការងារ និងដោយផ្អែកតាមស្ថានភាពសុខភាព និងសុខភាពផ្លូវចិត្តរបស់ពួកគេ ។

**ង. ការសន្ទនាសង្គម**

ការអនុវត្តន៍នូវគោលនយោបាយ និងកម្មវិធីស្តីពីមេរោគអេដស៍/ជំងឺអេដស៍ អាចទទួលបាននូវជោគជ័យ ដរាបណាមានកិច្ចសហប្រតិបត្តិការ និងការជឿទុកចិត្តរវាងនិយោជក កម្មករនិយោជិត និងតំណាងរបស់ពួកគេ និងមន្ត្រីរាជការ ហើយបើជាករណីចាំបាច់នោះ គួរមានការចូលរួមយ៉ាងសកម្មពីកម្មករនិយោជិត ដែលផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ និងអ្នករងគ្រោះដោយសារជំងឺអេដស៍ ។

**ច. ការពិនិត្យឈាមរកមេរោគអេដស៍ក្នុងគោលបំណងបដិសេធពីការងារ**

មិនត្រូវទាមទារឱ្យអ្នកដាក់ពាក្យសុំបំរើការងារ ឬអ្នកកំពុងបំពេញការងារ ពិនិត្យឈាមរកមេរោគអេដស៍/ជំងឺអេដស៍ឡើយ ។ ✝

**ឌ. ការរក្សាភាពសម្ងាត់**

គ្មានហេតុផលណាមួយដែលតម្រូវឱ្យអ្នកដាក់ពាក្យសុំបំរើការងារ ឬកម្មករនិយោជិត បង្ហាញពីពត៌មានផ្ទាល់ខ្លួន ដែលទាក់ទងនឹងមេរោគអេដស៍/ជំងឺអេដស៍ឡើយ ។ ហើយកម្មករនិយោជិតក៏មិនតម្រូវឱ្យបង្ហាញពីពត៌មាន ផ្ទាល់ខ្លួនទាំងនេះ ទៅដល់កម្មករនិយោជិតដទៃទៀតដែរ ។ ការបើកនែកមើលពត៌មានផ្ទាល់ខ្លួនទាំងឡាយណា ដែលទាក់ទងនឹងមេរោគអេដស៍/ជំងឺអេដស៍ ត្រូវធ្វើឡើងតាមគោលការណ៍រក្សាការសម្ងាត់ ដែលសមស្រប នឹងគោលការណ៍របស់អង្គការអន្តរជាតិខាងការងារ ស្តីពីការការពារពត៌មានផ្ទាល់ខ្លួន របស់កម្មករនិយោជិត ។

**ជ. ការបន្តរក្សាទំនាក់ទំនងក្នុងការបំរើការងារ**

ការឆ្លងមេរោគអេដស៍ ពុំមែនជាមូលហេតុនៃការបញ្ឈប់ពីការងារឡើយ ។ បើធៀបទៅនឹងលក្ខខណ្ឌ ផ្សេងៗនោះ អ្នកផ្ទុកមេរោគអេដស៍ ក៏អាចបន្តការងារបាន ដរាបណាដែលគ្រូពេទ្យបញ្ជាក់ថានៅមានសុខភាព មាំមួន ហើយអាចបំពេញការងារបាន ។

**ឈ. ការបង្ការ**

គេអាចបង្ការការចម្លងមេរោគអេដស៍បាន ។ ការបង្ការគ្រប់ផ្លូវចម្លងមេរោគ អាចធ្វើឡើងតាមរយៈយុទ្ធសាស្ត្រ មួយចំនួនដែលផ្តោតចំទៅនឹងស្ថានភាពជាក់ស្តែងរបស់ប្រទេស ហើយសមស្របនឹងវប្បធម៌ទៀតផង ។ ការបង្ការអាចធ្វើឡើងបានតាមរយៈការផ្លាស់ប្តូរឥរិយាបថនៃការប្រព្រឹត្ត ការបង្កើនចំណេះដឹង ការព្យាបាល និងការបង្កើតឱ្យមានបរិយាកាសសង្គមដោយគ្មានការរើសអើង ។

ដៃគូនានាដែលបំរើការងារសង្គម សុទ្ធតែមានតួនាទីក្នុងការលើកកំពស់ការបង្ការ ជាពិសេសធ្វើយ៉ាងណាឱ្យមាន ការផ្លាស់ប្តូរឥរិយាបថនិងការប្រព្រឹត្ត តាមរយៈការផ្តល់ពត៌មាន ការអប់រំ និងការកែប្រែកត្តាសង្គម សេដ្ឋកិច្ច ដែលនាំឱ្យមានការប្រឈមនឹងការឆ្លងមេរោគអេដស៍/ជំងឺអេដស៍ ។

**ញ. ការថែទាំ និងការគាំទ្រ**

នៅក្នុងពិភពការងារ សាមគ្គីភាព ការថែទាំ និងការគាំទ្រ គួរជាមគ្គុទ្ទេសក៍ក្នុងការឆ្លើយតបទៅនឹងមេរោគ អេដស៍ ។ កម្មករនិយោជិតទាំងអស់ រួមទាំងកម្មករនិយោជិតដែលផ្ទុកមេរោគអេដស៍ មានសិទ្ធិគ្រប់គ្រាន់ ក្នុង ការទទួលបាននូវសេវាសុខភាព ។ មិនត្រូវមានការរើសអើងដល់អ្នកទាំងនោះ និងគ្រួសារពួកគេ ក្នុងការប្រើ ប្រាស់សេវា និងការទទួលផលកំរៃពីកម្មវិធីសន្តិសុខសង្គម និងផែនការផ្តល់ការឧបត្ថម្ភផ្សេងៗដែលបានមកពី ការងារឡើយ ។

**ប្រការ ១៣.-**

នាយកដ្ឋានពេទ្យការងារនៃអគ្គនាយកដ្ឋានការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមានភារកិច្ច ដូចតទៅ៖ ⁊⁊

-ផ្តល់ជំនួយផ្នែកបច្ចេកទេស ឯកសារ វិធីសាស្ត្រផ្សេងៗដល់ក្រុមការងារអេដស៍ ឬ គណៈកម្មការអេដស៍នៃសហគ្រាស គ្រឹះស្ថាននានា សំដៅជួយដល់ក្រុមការងារ ឬគណៈកម្មការទាំងនោះអាចដំណើរការបានជោគជ័យ ។

-ចុះត្រួតពិនិត្យ និងតាមដានការអនុវត្តន៍បទប្បញ្ញត្តិនៃប្រកាសនេះជាប្រចាំ ។

-ផ្សព្វផ្សាយ ពន្យល់និយោជកនៃសហគ្រាស គ្រឹះស្ថាន ដូចមានចែងក្នុង ប្រការ២ ខាងលើឱ្យយល់ជ្រួតជ្រាប ដើម្បីអនុវត្តឱ្យបានត្រឹមត្រូវតាមបទប្បញ្ញត្តិនៃប្រកាសនេះ ។

-ចាត់វិធានការផ្តល់ដំបូន្មាន ហើយក្នុងករណីធ្ងន់ធ្ងរ ចាត់វិធានការដាក់កំហិតចំពោះនិយោជកដែលពុំព្រមអនុវត្តឱ្យបានត្រឹមត្រូវតាមបទប្បញ្ញត្តិនៃប្រកាសនេះ ។

-បូកសរុប និងលើកសំណើផ្តល់ការសរសើរ ឬលើកទឹកចិត្ត តាមរូបភាពផ្សេងៗជូនដល់និយោជកដែលខិតខំអនុវត្តបទប្បញ្ញត្តិនៃប្រកាសនេះបានល្អ ។

**ប្រការ ១៤.-**

ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/.

រដ្ឋមន្ត្រី

ញ៉ែប-ប៊ុនជិន

**ចម្លងជូន:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួងពាក់ព័ន្ធ
-*អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍*
"ដើម្បីជូនជ្រាប"
-អគ្គនាយកដ្ឋានការងារ និងអគ្គនាយកដ្ឋានបណ្តុះបណ្តាលវិជ្ជាជីវៈ
"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
-គ្រប់មន្ទីរ ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
"ដើម្បីផ្សព្វផ្សាយ និង អនុវត្ត"
-សមាគមនិយោជក"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
-សហភាពសហព័ន្ធសហជីព សហព័ន្ធសហជីព សហជីពមូលដ្ឋាន
"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
-គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
-រាជកិច្ច
-កាលប្បវត្តិ និងឯកសារ